PROSUR INSURANCE PLC.

# នីតិវិធីនៃការទាមទារសំណងសម្រាប់បណ្ណសន្យារ៉ាប់រងលើការដឹកជញ្ជូនទំនិញ

ឯកសារនេះបង្ហាញពីជំហានដែលត្រូវអនុវត្ត និងតម្រូវការឯកសារផ្សេងៗនៅពេលដែលលោកអ្នកស្នើសុំការទាមទារសំណងទៅកាន់ក្រុមហ៊ុន ប្រូសួរ អ៊ិនសួរេន ម.ក។

## នីតិវិធីនៃការទាមទារសំណង

សូមប្រញាប់ទាក់ទង ឬជូនដំណឹងទៅកាន់ក្រុមការងារផ្នែកទាមទារសំណងរបស់ក្រុមហ៊ុន ប្រូសួរ អ៊ិនសួរេន ម.ក និង/ឬភ្នាក់ងារដោះស្រាយសំណងដែលមានបញ្ជាក់ក្នុងបណ្ណសន្យារ៉ាប់រង។ លោកអ្នកនឹងត្រូវបានណែនាំអំពីជំហាននីមួយៗដែលត្រូវអនុវត្ត។

ព័ត៌មាន និងឯកសារដែលតម្រូវចំពោះការទាមទារសំណងមានដូចខាងក្រោម៖

| ការទាមទារសំណងលើការខូចខាតទំនិញ | |
|---|---|
| | ទាក់ទងភ្នាក់ងារដោះស្រាយសំណង ដែលមានបញ្ជាក់ក្នុងបណ្ណសន្យារ៉ាប់រង ឬវិញ្ញាបនប័ត្រធានារ៉ាប់រង ដើម្បីចុះត្រួតពិនិត្យដល់កន្លែងកើតហេតុផ្ទាល់។ |
| | ដាក់ស្នើសុំការទាមទារជាលាយលក្ខណ៍អក្សរ ទៅកាន់ក្រុមហ៊ុនដឹកជញ្ជូន អ្នកផ្ញើ អ្នកទទួល ឬភាគីពាក់ព័ន្ធផ្សេងទៀត សម្រាប់ឥវ៉ាន់ដែលបាត់បង់ ឬខូចខាត។ |
| | អនុវត្តវិធានការសមស្របណាមួយដើម្បីបង្ការ ឬកាត់បន្ថយការបាត់បង់ទៅលើទំនិញដែលនៅសល់។ |
| | ថែទាំទំនិញដែលខូចខាត និងរក្សាទុកទំនិញដែលអាចសង្គ្រោះបាន។ |

**សូមផ្តល់ឯកសារដូចខាងក្រោមឱ្យបានឆាប់រហ័ស៖**

១. បណ្ណសន្យារ៉ាប់រងច្បាប់ដើម ឬវិញ្ញាបនប័ត្រធានារ៉ាប់រង
២. វិក្កយបត្រនៃការដឹកជញ្ជូនច្បាប់ដើម ឬថតចម្លង រួមទាំងព័ត៌មានលម្អិតនៃការដឹកជញ្ជូន និង/ឬបរិមាណទម្ងន់ (ប្រសិនបើមាន)
៣. តារាងទំនិញដែលបានដឹកជញ្ជូនច្បាប់ដើម និង/ឬកិច្ចសន្យាដឹកជញ្ជូនផ្សេងៗ
៤. របាយការណ៍ចុះត្រួតពិនិត្យ ឬរូបថត ឬឯកសារផ្សេងៗ ដើម្បីបង្ហាញពីកម្រិតនៃការបាត់បង់ ឬខូចខាត

៥. សំបុត្រទំនាក់ទំនងជាមួយក្រុមហ៊ុនដឹកជញ្ជូន និងភាគីផ្សេងទៀត អំពីការទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាត
៦. បញ្ជីវេចខ្ចប់
៧. ប័ណ្ណប្រគល់ទំនិញ (ប្រសិនបើមាន)
៨. វិក្កយបត្រទាមទារសំណង

PROSUR
INSURANCE PLC.

## Marine Cargo Insurance Claim

This section provides information on the steps required and the documents needed when you submit a claim to Prosur Insurance.

## Claims Process

Please contact or notify Prosur claims team and/or the settling agent named in the policy immediately. You will be guided on all the initial steps to be taken.

The information and documents (if applicable) required are as follows: -

| Cargo Claim | |
|---|---|
| | Contact the settling agent named in the insurance policy or certificate to conduct a survey |
| | File a claim in writing to the carriers, forwarders, bailees or other concerned parties for any missing or damaged packages |
| | Take reasonable measures to avert or minimize loss to the remaining cargo |
| | Take proper care of the damaged cargo and keep any salvage |

**Provide the following documents without delay:**

1. Original policy or certificate of insurance
2. Original or copy of the shipping invoices, together with shipping specification and/or weight notes (if any)
3. Original bill of lading and/or other contract of carriage
4. Survey report or Photograph(s) or other documentary evidence to show the extent of the loss or damage
5. Correspondence exchanged with the Carriers and other Parties regarding their liability for the loss or damage
6. Packing list
7. Delivery Order (if applicable)
8. Claim bill